ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ 07.418/01 គ.ជ.ប

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើត និង កំណត់ទីតាំងការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម ១២៩៧.០៦ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស.រកម ០៣០១.០៤ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ ជ.ស.រកត ០១៩៨.០៤២ ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ២ និងសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ០១ សប្រក ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០១ ស្តីពីកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៣២៥ សជណ ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០០១ អំពីវិញ្ញត្តិ ស្តីពីព្រះរាជក្រម ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។
- តាមសំណើរបស់អគ្គលេខាធិការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## សម្រេច

ប្រការ ១ : ត្រូវបានបង្កើតការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត នៅគ្រប់ខេត្ត ក្រុងទាំង ២៤ ក្នុងទូទាំងប្រទេស ដែលមានចំនួនសរុប ១២.៣៧៣ការិយាល័យ សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០២ ។

ប្រការ ២ : ទីតាំងនៃការិយាល័យ ដូចប្រការ ១ ត្រូវបានកំណត់ដូចមានក្នុងឯកសារភ្ជាប់ជាមួយនឹងសេចក្តីសម្រេចនេះ ។

ប្រការ ៣ : អនុលោមតាមកថាខ័ណ្ឌទី ១ មាត្រា ៣១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ទីតាំងការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ដូចប្រការ ១ នឹងក្លាយទៅជាទីតាំងការិយាល័យបោះឆ្នោតនៅពេលបោះឆ្នោត និងជាទីតាំងការិយាល័យរាប់សន្លឹកឆ្នោតនៅពេលរាប់សន្លឹកឆ្នោត លើកលែងតែមានការសម្រេចផ្សេងពីនេះ ដោយ គជប ។

ប្រការ ៤ : គ្រប់អនុគណៈកម្មាធិការអចិន្ត្រៃយ៍នៃ គជប អគ្គលេខាធិការដ្ឋាននៃ គជប គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ,ថ្ងៃទី 07 ខែ 07 ឆ្នាំ ២០០១

**ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ចំលងជូន :**

- ខុទ្ទកាល័យព្រឹទ្ធសភា
- ខុទ្ទកាល័យរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ដូចប្រការ ៤
- ឯកសារ_កាលប្បវត្តិ